ផ្សារមូលបត្រកម្ពុជា
CSX
ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីជូនព័ត៌មាន
អំពី
**កម្មវិធី "ឆ្ពោះទៅកាន់ការចុះបញ្ជីនៅ ផ.ម.ក."**
**ប្រធានបទ "ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ និងការរៀបចំឯកសារចុះបញ្ជី"**

នៅថ្ងៃទី **១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤**នេះ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាហៅកាត់ថា (ផ.ម.ក.) ដែលជាក្រុមហ៊ុនចំរុះរវាងរាជរដ្ឋាភិបាលកម្ពុជា និងផ្សារមូលបត្រកូរ៉េ បានរៀបចំកម្មវិធី **"ឆ្ពោះទៅការចុះបញ្ជីនៅ ផ.ម.ក."** ប្រធានបទ "ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ និងការរៀបចំឯកសារចុះបញ្ជី" ក្រោមអធិបតីភាព លោក **ហុង សុហួរ** អគ្គនាយកក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ កម្មវិធីនេះមានការអញ្ជើញចូលរួមពីបណ្តាក្រុមហ៊ុនធំៗជាច្រើននៅក្នុងប្រទេសកម្ពុជា ដែលជាក្រុមហ៊ុនមានសក្តានុពលក្នុងការឈានជើងចូលទីផ្សារភាគហ៊ុន។

កម្មវិធីនេះធ្វើឡើងក្នុងគោលបំណងជម្រុញឱ្យមានការយល់ដឹងកាន់តែប្រសើរឡើង អំពីសក្តានុពលនៃការកៀរគរទុន និងនីតិវិធីនៃការចុះបញ្ជីនៅ ផ.ម.ក. តាមរយៈការពិភាក្សាស៊ីជម្រៅរវាងវាគ្មិនជំនាញ និងក្រុមហ៊ុនសក្តានុពលនៅកម្ពុជា។ កម្មវិធី **"ឆ្ពោះទៅការចុះបញ្ជីនៅ ផ.ម.ក."**នេះ នឹងប្រព្រឹត្តទៅជាបន្តបន្ទាប់ក្នុងរយៈពេល៥ខែ ដោយគិតចាប់ពីខែកុម្ភៈ ឆ្នាំ២០១៤ រហូតដល់ ខែមិថុនា ឆ្នាំ២០១៤។ ប្រធានបទដែលនឹងត្រូវលើកឡើងក្នុងកម្មវិធីនេះមាន៥ប្រធានបទ។

ប្រធានបទ "ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ និងការរៀបចំឯកសារចុះបញ្ជី"នេះ គឺជាប្រធានបទទី១ ដែលមានវាគ្មិនកិត្តិយសអញ្ជើញមកពីក្រុមហ៊ុនតុងយ៉ាងស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី។ ចំណែកប្រធានបទទី២គឺពាក់ព័ន្ធនឹង "ការត្រៀមរៀបចំផ្នែកគណនេយ្យ" នឹងប្រព្រឹត្តទៅនៅខែមិនា ដោយវាគ្មិនកិត្តិយសមកពីក្រុមហ៊ុនគណនេយ្យ PricewaterhouseCoopers ប្រធានបទទី៣គឺពាក់ព័ន្ធនឹង "ការត្រៀមរៀបចំផ្នែកច្បាប់" នឹងប្រព្រឹតទៅនៅខែមេសា ដោយវាគ្មិនកិត្តិយសមកពីក្រុមហ៊ុនមេធាវី HBS ប្រធានបទទី៤គឺពាក់ព័ន្ធ "ការវាយតម្លៃទ្រព្យកម្មសិទ្ធិ និងកំណត់ថ្លៃមូលបត្រ" នឹងប្រព្រឹត្តទៅនៅខែឧសភា ដោយវាគ្មិនកិត្តិយសមកពីក្រុមហ៊ុនកម្ពុស៊ីយូរីធី ភីអិលស៊ី និងប្រធានបទទី៥គឺពាក់ព័ន្ធ "ការស្ទាបស្ទង់ថ្លៃ និងការធ្វើបរិវិសកម្ម" នឹងប្រព្រឹត្តទៅនៅខែមិថុនា ដោយវាគ្មិនកិត្តិយសមកពីក្រុមហ៊ុនភ្នំពេញស៊ីយូរីធី ភីអិលស៊ី។

អាសយដ្ឋានបណ្តោះអាសន្ន: ជាន់ទី២៥ វិមានកាណាឌីយ៉ា លេខ៣១៥ វិថីព្រះអង្គឌួង (លេខ១១០) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៩៥ ៨៨ ៨៨ ទូរសារ: (៨៥៥) ២៣ ៩៥ ៩៥ ៥៨ អ៊ីម៉ែល: info@csx.com.kh គេហទំព័រ: http://www.csx.com.kh